លូតលាស់
ទាំងអស់គ្នា

ការបដិសេធ៖

សៀវភៅកុមារនេះ ត្រូវបានរៀបចំឡើងក្រោមជំនួយសប្បុរសធម៌របស់ពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការលេខ No. AID-442-A-14-00006។ ខ្លឹមសារនៃសៀវភៅនេះមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

USAID ជំនួយពីពលរដ្ឋអាមេរិក

WFP World Food Programme

Save the Children

SNV

THE MANOFF GROUP

# រឿង ចិន្តាពូកែចង់ដឹងចង់យល់ អំពីបន្លែចម្រុះ





ចិន្តាជិះកង់របស់នាងទៅសាលារៀនជារៀងរាល់ថ្ងៃ។ ថ្ងៃមួយ នាងបានរៀនសូត្រអំពីរុក្ខជាតិ ពីលោកគ្រូរបស់នាង។ នាងចូលចិត្តបន្លែ និងផ្លែឈើទាំងឡាយដែលអាចយកមកធ្វើម្ហូបអាហារផ្សេងៗបាន។

អ្នកគ្រូក៏បានបង្រៀនចិន្តាដែរ អំពីអត្ថប្រយោជន៍នៃអាហារចម្រុះសម្រាប់សុខភាព និងការលូតលាស់របស់កុមារ។ ចិន្តានៅតែចង់ដឹង និងចង់យល់បន្ថែមទៀត . . .



ដូច្នេះ នៅពេលពូរបស់នាងដែលជាមន្ត្រីកសិកម្មមកលេង ចិន្តាបានត្រៀមរួចជាស្រេច ដើម្បីសួរសំនួរជាច្រើនទៅគាត់។

ចិន្តា៖ ពូ! តើបន្លែណាខ្លះដែលលូតលាស់លឿន និងងាយស្រួលដាំដុះនៅតាមផ្ទះ?





ពូ៖ អូ! មានច្រើនណាស់ក្មួយ។
បន្លែទាំងនោះមានដូចជា ផ្ទី សណ្តែកកួរ ល្ពៅ ត្រប់វែង និងត្រកួន។ ក្មួយអាចដាំវានៅក្នុងសួនបន្លែតូចមួយបាន ហើយអ្វី ដែលក្មួយត្រូវការគឺ ដី ទឹក

ចិន្តា៖ អរគុណពូ! ខ្ញុំដឹងថាបន្លែទាំងអស់មានរសជាតិផ្សេងៗគ្នា ហើយខ្ញុំចូលចិត្តល្ពៅជាងគេ។ ប៉ុន្តែ តើបន្លែណាខ្លះដែលល្អបំផុតសម្រាប់កុមារតូចៗ?



ពូ៖ មានបន្លែជាច្រើនដែលផ្ដល់ផលល្អសម្រាប់កុមារ ដែលមានអាយុចាប់ពីប្រាំមួយខែឡើងទៅ។ បន្លែដែលមានពណ៌បៃតងដូចជា ផ្ទីសណ្ដែកកួរ និងត្រកួន ជួយឲ្យឆ្អឹងកុមាររឹងមាំ ជួយការពារពីជម្ងឺ និងធ្វើឲ្យមានសុខភាពល្អ។ បន្លែដែលមានពណ៌លឿងដូចជា ល្ពៅ និងដំឡូងជ្វា ផ្ដល់ផលល្អដល់ភ្នែក។

បន្ទាប់ពីស្ដាប់ហើយ ចិន្ដាមានសេចក្ដីរីករាយយ៉ាងខ្លាំង។

ប្អូនប្រុសរបស់ចិន្ដា ឈ្មោះចាន់នី មានអាយុជិតមួយឆ្នាំហើយ។ ចិន្ដាតែងតែគិតគូរដល់សុខភាព និងការលូតលាស់របស់ចាន់នី។ នាងចង់ក្លាយជាវេជ្ជបណ្ឌិតម្នាក់ដែលមានជំនាញផ្នែកកុមារ។



នៅព្រឹកបន្ទាប់ ចិន្តាបានជួយឪពុករបស់នាងធ្វើសួនបន្លែតូចមួយ សម្រាប់គ្រួសារទាំងមូល។

ចិន្តានិយាយទៅកាន់ឪពុករបស់នាងថា៖ ពុក! តោះយើងដាំល្ពៅ ត្រកួន និងសណ្តែកកួរ។ ខ្ញុំចង់ឲ្យអាអូនចាន់នីលូតលាស់ មានសុខភាពល្អ មានភាពសប្បាយរីករាយ និងមានប្រាជ្ញាឈ្លាសវៃ។

មួយរយៈក្រោយមក ចិន្តាបានជួយម្តាយរបស់នាងចម្អិនសម្លកកូរ។ នាងបានជួយបេះបន្លែដែលនាង និងឪពុករបស់នាងបានដាំនៅជុំវិញផ្ទះ និងបានបន្ថែមម្ទេសក្រឹល្អិតដែលពួកគេបានធ្វើជាមួយគ្នាទៅក្នុងសម្លនោះ។



គ្រប់ៗគ្នា រួមទាំងចាន់នី ដែលកំពុងតែលូតលាស់យ៉ាងឆាប់រហ័ស បានលាងដៃជាមួយសាប៊ូនៅមុនពេលញ៉ាំអាហារ។ ចិន្តាបានជួយចាន់នីលាងដៃទាំងពីរជាមួយសាប៊ូ ហើយលាងជម្រះយ៉ាងស្អាត។

ចិន្តានិយាយទៅកាន់ចាន់នីថា៖ ម៉ែថា អាអូនឯងក៏ត្រូវលាងសម្អាតដៃនៅមុនពេលញ៉ាំអាហារដែរ គឺមិនអាចលើកលែងបានទេ!





សមាជិកគ្រួសារទាំងអស់ចូលចិត្ត សម្លកកូរមានបង់បន្លែចម្រុះ ដែលពួកគេបានដាំ។

ចិន្តា៖ ញុាំទៅចាន់នី! បន្លែនិងត្រីហ្នឹងជួយឲ្យអាអូនឯងលូតលាស់លឿន មានសុខភាពល្អ រឹងមាំ និងឆ្លាតដូចបង!